**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# លិខិតថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈ**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមព្រះរាជានុញ្ញាតសម្តែងនូវអំណរសាទរ និង មនោសញ្ចេតនារំភើបសប្បាយរីករាយយ៉ាងក្រៃលែងក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈ** គម្រប់ ៦២ យាងចូល ៦៣ ព្រះវស្សា ត្រូវនឹងថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៥ ។ ក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំសូមថ្វាយព្រះពរ **ព្រះករុណាព្រះមហាក្សត្រ** សូមមានព្រះជន្មាយុយឺនយូរ ព្រះរាជសុខភាពល្អបរិបូណ៌ ព្រះរាជបញ្ញាញាណវាងវៃ ដើម្បីគង់ប្រថាប់ក្នុងព្រះបរមសិរីរាជសម្បត្តិ និងម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ យូរអង្វែងតរៀងទៅ ។

ក្នុងទិវាដ៏មហាប្រសើរនេះ ទូលព្រះបង្គំយើងខ្ញុំ ជាកូនចៅព្រះអង្គ សូមព្រះរាជានុញ្ញាតក្រាបបង្គំទូលថ្វាយនូវកត្តញ្ញុតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ចំពោះព្រះមហាករុណាធិគុណដ៏ធំធេង ដែលព្រះករុណាជាអម្ចាស់ បានប្រោសប្រទានដល់ប្រជារាស្ត្រ ជាកូនចៅព្រះអង្គ ក្នុងខណៈដែលព្រះអង្គទ្រង់គង់ជានិមិត្តរូបដ៏ប្រសើរខ្ពង់ខ្ពស់បំផុតនៃអធិបតេយ្យភាព និង ឯករាជ្យភាព ព្រមទាំងតាមរយៈព្រះរាជបេសកកម្មទ្រទ្រង់វប្បធម៌ជាតិ និង សកម្មភាពមនុស្សធម៌ដ៏ថ្លៃថ្លាបំផុត ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ និង បុគ្គលិកនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទូលព្រះបង្គំយើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរថ្លៃថ្លាថ្វាយ **ព្រះករុណាព្រះមហាក្សត្រ** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិ ជាទី គោរពសក្ការៈ** សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

អៀង _ មូលី

អាសយដ្ឋាន: អគារលេខ ១៦ ផ្លូវលេខ ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់ II ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារ (៨៥៥-២៣) ៨៨៥ ១២៩